SEI Stockholm Environment Institute

# ការបំពុលខ្យល់និងសុខភាពកម្មករក្នុងវិស័យកាត់ដេរនៅកម្ពុជា



## គោលនយោបាយសង្ខេបរបស់វិទ្យាស្ថានបរិស្ថានស្តុកខុមខែមីនា ឆ្នាំ២០២៣


លោក ហ៊ឹម ច័ន្ទដេត[១]

លោក អ៊ឹង ឆាយប៉ោ[១]

លោក យឹម រស្មី[២]

បណ្ឌិត Diane Archer[៣]

[១] នាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់ សំឡេង និងរំញ័រ អគ្គនាយកដ្ឋានគាំពារបរិស្ថាននៃក្រសួងបរិស្ថាន ប្រទេសកម្ពុជា

[២]ទីប្រឹក្សាជាតិ

[៣] វិទ្យាស្ថានបរិស្ថានស្តុកខុម


គោលនយោបាយសង្ខេបនេះ ដកស្រង់ចេញពីរបាយការណ៍ពេញលេញដែលបានរៀបចំដោយក្រសួងបរិស្ថាន៖ លោក ហ៊ឹម ច័ន្ទដេត លោក អ៊ឹង ឆាយប៉ោ លោក សំ សុខឃីម៉េង លោកស្រី សាន ដាណា លោក យឹម រស្មី ឆ្នាំ២០២៣ ស្តីពីការយល់ដឹងការបំពុលខ្យល់ និងផលប៉ះពាល់លើ សុខភាពកម្មករក្នុងវិស័យកាត់ដេរ៖ ករណីសិក្សាអំពីប្រទេសកម្ពុជា។ ក្រសួងបរិស្ថាន ប្រទេស កម្ពុជា។

រូបភាព (ខាងលើ)៖ ផ្តល់ដោយលោក ហ៊ឹម ច័ន្ទដេត

IMAGE (ABOVE): © ANDERS BLOMQVIST / GETTY

## សារសំខាន់ៗ

- ក្រុមការងារក្រសួងបរិស្ថានបានធ្វើការត្រួតពិនិត្យគុណភាពខ្យល់នៅតាមរោងចក្រកាត់ដេរមួយចំនួន ដោយលទ្ធផលបានបង្ហាញថាគុណភាពខ្យល់នៅតាមរោងចក្រកាត់ដេរ ទាំងនោះ គឺស្ថិតនៅក្រោមស្តង់ដារគុណភាពខ្យល់ជាតិ និងគោលការណ៍ណែនាំរបស់ អង្គការសុខភាពពិភពលោក (WHO)។ ក៏ប៉ុន្តែគុណភាពខ្យល់ក្នុងអគារ និងក្រៅអគារនៅ តាមរោងចក្រខ្លះលើសពីកម្រិតស្តង់ដារកំណត់។
- តាមរយៈការជួបសម្ភាសន៍ មានម្ចាស់រោងចក្រតែពាក់កណ្តាលប៉ុណ្ណោះដែលបានធ្វើការ ត្រួតពិនិត្យគុណភាពខ្យល់នៅក្នុងរោងចក្រជាទៀងទាត់ (រៀងរាល់ ៦ខែម្តង ឬ មួយឆ្នាំម្តង)។ ការធ្វើបែបនេះវាមិនគ្រប់គ្រាន់ទេដើម្បីធានាថាកម្មករ គ្រប់រូបបានដឹងថា ពួកគេបានរងផលប៉ះពាល់ពីការបំពុលខ្យល់។
- កម្មកររោងចក្រស្ទើរតែទាំងអស់ (៩៩%) ដែលបានសម្ភាសន៍ បានឱ្យដឹងថាគុណភាពខ្យល់ នៅកន្លែងធ្វើការរបស់ពួកគេគឺ អាចទទួលយកបាន ក៏ប៉ុន្តែកម្មករភាគច្រើនបានគិតថា «ការបំពុលខ្យល់» គឺសំដៅលើសីតុណ្ហភាពនៅក្នុងរោងចក្រទៅវិញ។ យ៉ាងហោចណាស់ កម្មករដែលបានសម្ភាសន៍ទាំងអស់មានរោគសញ្ញាចំនួនមួយទាក់ទងនឹងការ បំពុលខ្យល់។
- វិស័យកាត់ដេរបានផ្តល់ការងារដល់កម្មករស្ត្រីភាគច្រើន ហេតុនេះហើយគោលនយោបាយ និងការបង្ការចំពោះការបំពុលខ្យល់គួរត្រូវបានលើកឡើងដើម្បីឆ្លើយតបនឹងតម្រូវការ ជាក់លាក់របស់កម្មករស្ត្រី។

វិស័យកាត់ដេរគឺផ្នែកដ៏សំខាន់មួយក្នុងឧស្សាហកម្មផលិតកម្មក្នុងប្រទេសកម្ពុជាដែលរួមចំណែកចំនួន ១៩% ដល់ផលិតផលជាតិសរុប និង ៧២% នៃប្រាក់ចំណូលនាំចេញរបស់ប្រទេស។ គិតត្រឹមឆ្នាំ២០១៥ ប្រទេសកម្ពុជាមានរោងចក្រកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងដែលបានចុះបញ្ជីជាផ្លូវការចំនួន ៦៤០ រោងចក្រ (Merk & Nuon, 2016)។ រោងចក្រកាត់ដេរ សម្លៀកបំពាក់ និងស្បែកជើងផ្តល់ការងារប្រហែល ៧៧% ក្នុងចំណោមផលិតកម្មទាំងអស់នៅក្នុងប្រទេសកម្ពុជា (Merk & Nuon, 2016)។

វិស័យនេះក៏ជាវិស័យធំបំផុតសម្រាប់ការងារផ្លូវការ និងមានកម្លាំងពលកម្មជាស្ត្រីភាគច្រើនផងដែរ៖ រោងចក្រវាយនភណ្ឌ និងកាត់ដេរសម្លៀកបំពាក់ផ្តល់ការងារដល់ស្ត្រីប្រមាណ ៨០% (ILO, 2018) ហើយវិស័យនេះតំណាងឱ្យប្រហែល ៨% នៃការងារសរុបរបស់ស្ត្រី និងជាងមួយភាគបីនៃការងារដែលទទួលបានប្រាក់ ចំណូលសម្រាប់ស្ត្រីទាំងអស់នៅកម្ពុជា (Asian Development Bank, 2013)។ វិស័យផលិតកម្មផ្តល់ការងារដល់ស្ត្រីចំនួន ៨៤០ ០០០ នាក់ បើធៀបនឹងកម្មករបុរសដែលមានចំនួន ៤៧៥ ០០០ នាក់ (Kingdom of Cambodia, 2019)

វិស័យកាត់ដេរបានពង្រីកការងារផ្លូវការរបស់ស្ត្រី និងគាំទ្រដល់សមាជិកគ្រួសាររបស់ពួកគេរាប់ពាន់នាក់ដោយប្រយោល រួមទាំងអ្នកផ្តល់សេវា (អ្នកលក់ដូរ) នៅក្នុងតំបន់ឧស្សាហកម្ម ដូចជាអ្នកលក់ម្ហូបអាហារផងដែរ (Lawreniuk & Nuon, 2022)។ ទោះជាយ៉ាងណាក៏ដោយវិស័យនេះក៏បង្កើតនូវរោងចក្រដែលធ្វើកិច្ចសន្យាបន្តគ្នាដោយមិនបានចុះបញ្ជី ហើយមិនស្ថិតនៅក្រោម ការទទួលខុសត្រូវ របស់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ហើយវាប្រហែលជាមិនបានអនុវត្តតាមគោលការណ៍នៃសិទ្ធិការងារ និងបទប្បញ្ញត្តិនានា ដែលនាំឱ្យមានការរំលោភបំពានសិទ្ធិកម្មករ ព្រមទាំងលក្ខខណ្ឌការងារដែលមិនមានសុវត្ថិភាពផងដែរ។

ខណៈពេលដែលវិស័យកាត់ដេរដើរតួជាឆ្អឹងខ្នងសេដ្ឋកិច្ចរបស់កម្ពុជា និងបង្កើតការងារយ៉ាងច្រើនក៏ដោយ វាគឺជាឧស្សាហកម្មដែលមានការបំពុលខ្យល់យ៉ាងខ្លាំង រួមជាមួយនឹងការជាប់ពាក់ព័ន្ធជាប្រចាំចំពោះការមិនគោរពសិទ្ធិការងារផងដែរ។ វិស័យនេះបានបញ្ចេញសារធាតុបំពុលខ្យល់ តាមរយៈការប្រើប្រាស់ថាមពលជាចម្បង ការបញ្ចេញកាកសំណល់រឹង និងគ្រោះថ្នាក់ ការរំខានដោយសំឡេង និងការបង្ហូរទឹកកករក្អក់ជាដើម (MOE & GGGI, 2016) ។ ទោះបីជាយ៉ាងនេះក្តី ផលប៉ះពាល់បរិស្ថានក្នុងវិស័យកាត់ដេរនៅកម្ពុជា ជាពិសេសទាក់ទងនឹងការបំពុលខ្យល់មិនទាន់ត្រូវបានគេដឹងច្បាស់ជាទូទៅនៅឡើយទេ ហើយបញ្ហានេះត្រូវបានគូសបញ្ជាក់នៅក្នុងការអភិវឌ្ឍន៍ផែនការខ្យល់ស្អាតឆ្នាំ ២០២១ របស់កម្ពុជា។

ដោយមានគោលបំណងដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងខាងលើ ព្រមទាំងមានកិច្ចសហការជាមួយវិទ្យាស្ថានបរិស្ថានស្តុកខុម (SEI) នាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់ និងសំឡេង និងរំញ័រនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន ក្រសួងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា បានអនុវត្តគម្រោងស្រាវជ្រាវមួយដើម្បីកែលម្អការយល់ដឹងអំពីការបំពុលខ្យល់ដែលចេញពីឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរសម្លៀកបំពាក់ និងផលប៉ះពាល់សុខភាពកម្មករក្នុងឧស្សាហកម្មកាត់ដេរនៅកម្ពុជា។ ការសិក្សានេះធ្វើឡើងតាមរយៈការសម្ភាសន៍ស៊ីជម្រៅជាមួយកម្មកររោងចក្រកាត់ដេរចំនួន ៣២៣ នាក់ មកពីរោងចក្រចំនួន ១៦ កិច្ចសម្ភាសន៍ជាមួយម្ចាស់រោងចក្រទាំង ១៦ និងការវិភាគទិន្នន័យដែលទទួលបានពីការធ្វើសម្ភាសន៍ ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ពីបទពិសោធន៍របស់អ្នកផ្តល់បទសម្ភាសន៍ទាំងអស់នោះស្តីពីការបំពុលខ្យល់នៅ កន្លែងការងារ។ ជាមួយគ្នានេះដែរ ការសិក្សាស្រាវជ្រាវនេះគ្រាន់តែជា

ការចងក្រងជាឯកសារអំពី រោគសញ្ញាមួយចំនួនដែលទាក់ទងនឹ ងការបំពុលខ្យល់នៅក្នុងរោងចក្រកាត់ដេរ វាមិ នមែនជាការសិ ក្សាស្រាវជ្រាវផ្នែកវេជ្ជសាស្រ្តដើ ម្បី វាយតម្លៃស្ថានភាពសុខភាពរបស់កម្មករ ហើ យក៏មិ នមែន ជាការស៊ើ បអង្កេត និ ងវាយតម្លៃពី ផលប៉ះពាល់នៃការបំពុលខ្យល់លើ ផលិ តកម្មរបស់រោងចក្រនោះដែរ។

លទ្ធផលនៃការសិ ក្សានេះ គឺ ជាការជូនដំណឹ ង និ ងផ្តល់ជាអនុសាសន៍ ដល់អ្នកបង្កើ តគោលនយោបាយក្នុងការធ្វើ អន្តរាគមន៍ ដើ ម្បី កែលម្អបរិ យាកាសនៅកន្លែងធ្វើ ការងារ រកវិ ធានការ កាត់បន្ថយប្រភពបំពុលខ្យល់នៅតាមរោងចក្រ និ ងដោះស្រាយបញ្ហាពាក់ព័ ន្ធផ្សេងទៀត។ ការធ្វើ អន្តរាគមន៍ បែបនេះនឹ ងជួយលើ កកម្ពស់សុខភាពរបស់កម្មករ ដែលជាផ្នែកមួយនៃសិ ទ្ធិ មនុស្ស ការធានាបាននូវកន្លែងធ្វើ ការប្រកបដោយសុវត្ថិ ភាព ព្រមទាំងផ្តល់ប្រយោជន៍ សម្រាប់កំណើ នសេដ្ឋកិ ច្ចរបស់ប្រទេសជាតិ ព្រោះថាកម្លាំងពលកម្មដែលមានសុខភាពល្អនឹ ងបង្កើ ន ផលិ តភាពឱ្យកាន់តែច្រើ នផងដែរ។

## លទ្ធផលនៃការសិ ក្សា

លទ្ធផលនៃការត្រួតពិ និ ត្យគុណភាពខ្យល់បានបង្ហាញថាប្រភពនៃការបំពុលនៅកន្លែងធ្វើ ការ រួមមាន ការបំភាយចេញពី បំពង់ផ្សែងនៃឡចំហាយ ឬម៉ាស៊ី នភ្លើ ង អគារធ្វើ ការតូចៗ ឬកន្លែងធ្វើ ការដែលមានកម្មករច្រើ ន ឬកន្លែងធ្វើ ការដែលខ្វះកង្ហារត្រជាក់ ឬប្រព័ ន្ធខ្យល់ចេញចូលជាដើ ម។ ខាងក្រោមនេះជាលទ្ធផលស្តី ពី ការត្រួតពិ និ ត្យគុណភាពខ្យល់ និ ងកិ ច្ចសម្ភាសន៍ ជាមួយកម្មករ និ ងម្ចាស់រោងចក្រ។

## ការបំភាយចេញពី រោងចក្រ

ការសិ ក្សាបានអង្កេតលើ រោងចក្រកាត់ដេរចំនួន ១៦ ក្នុងខេត្តចំនួន ៤ នៃប្រទេសកម្ពុជា រួមមាន៖ រាជធានី ភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និ ងខេត្តព្រះសី ហនុ។ នៅតាមរោងចក្រ នី មួយៗ មានទី តាំងចំនួនពី រកន្លែងត្រូវបានជ្រើ សរើ សដើ ម្បី ធ្វើ ការត្រួតពិ និ ត្យគុណភាពខ្យល់ គឺ នៅខាងក្នុងរោងចក្រដែលតំណាងឱ្យគុណភាពខ្យល់ក្នុងអគារ និ ងខាងក្រៅរោងចក្រដែលតំណាងឱ្យគុណភាពខ្យល់ក្រៅអគារ។ ទិ ន្នន័ យគុណភាពខ្យល់ក្នុងអគារ និ ងខាងក្រៅអគារត្រូវបានវាស់វែងក្នុងរយៈពេល៨ ម៉ោង ដោយចាប់ផ្តើ មពី ម៉ោង ៨:០០ព្រឹ ក ដល់ម៉ោង ៤:០០រសៀល ហើ យធ្វើ ការប្រៀបធៀបទៅនឹ ងស្ថានី យត្រួតពិ និ ត្យគុណភាពខ្យល់ដែលនៅជិ តបំផុត ដើ ម្បី ស្វែងយល់ពី ភាពខុសគ្នាពី កម្រិ តនៃផលប៉ះពាល់របស់កម្មករនៅក្នុងរោងចក្រ។

រោងចក្រទាំង ១៦ បានប្រើ ប្រាស់អគ្គិ សនី ជាប្រភពឥន្ធនៈសំខាន់។ ជាងនេះទៅទៀត រោងចក្រចំនួន១១ បានប្រើ ប្រាស់ហ្គាស (LPG) រោងចក្រចំនួន៥ បានប្រើ ប្រាស់អុស រោងចក្រចំនួន៣ បានប្រើ ប្រាស់ប្រេងម៉ាស៊ូត និ ងមានរោងចក្រមួយបានប្រើ ប្រាស់ជី វម៉ាស។ ក្នុងចំណោមរោងចក្រទាំង ១៦ មានរោងចក្រចំនួន៧ បានប្រើ ប្រាស់ប្រភពឥន្ធនៈចំនួន៣ រោងចក្រចំនួន៤ បានប្រើ ប្រាស់ប្រភពឥន្ធនៈចំនួន២ និ ងរោងចក្រចំនួន៤ បានប្រើ ប្រាស់អគ្គិ សនី ខណៈរោងចក្រចំនួន១ បានប្រើ ប្រាស់ប្រភពឥន្ធនៈចំនួន៤។ បើ ប្រៀបធៀបទៅនឹ ងប្រភពឥន្ធនៈផ្សេងទៀត ការប្រើ ប្រាស់អគ្គិ សនី មានការបំភាយនៅតែរោងចក្រអគ្គិ សនី តែប៉ុណ្ណោះ ចំណែកឯប្រភពឥន្ធនៈផ្សេងទៀតមានការបំភាយដោយផ្ទាល់នៅនឹ ងកន្លែងតែម្តង។

សមាសធាតុពុលចំនួនបួនប្រភេទត្រូវបានវាស់វែងសម្រាប់ការយកសំណាកគុណភាពខ្យល់៖ ភាគល្អិ តនិ ចលនៅកម្រិ ត២.៥ មី ក្រុង និ ងកម្រិ ត១០ មី ក្រុង (PM2.5 និ ង PM10) អាសូតអុកស៊ី ត (NOx) និ ងសមាសធាតុសរី រាង្គដែលមិ នមែនជាមេតាន (NMVOCs) ។ ក្នុងចំណោមការបំភាយសារធាតុ PM2.5 ដែលបានរកឃើ ញនៅតាមរោងចក្រ គឺ រោងចក្រចំនួនប្រាំដែលប្រើ ប្រាស់អុសជាប្រភពឥន្ធនៈ មានតួលេខខ្ពស់ជាងគេ ដែលនេះជាការបង្ហាញឱ្យឃើ ញថាការដុតឥន្ធនៈរឹង (ការដុតអុស) បង្កឱ្យមានការបំពុលខ្យល់ជាខ្លាំង បើ ប្រៀបធៀបទៅនឹ ងឥន្ធនៈផ្សេងទៀត (ម៉ាស៊ូត និ ងហ្គាស)។

ទាក់ទងនឹ ងការបំភាយសារធាតុបំពុលផ្សេងៗទៀត អាសូតអុកស៊ី ត (NOx) និ ងសមាសធាតុសរី រាង្គដែលមិ នមែនជាមេតាន (NMVOCs) រោងចក្រចំនួនប្រាំដែលប្រើ ប្រាស់អុសជាប្រភពឥន្ធនៈបញ្ចេញសារធាតុបំពុលខ្យល់ច្រើ នជាងគេ។ បើ ប្រៀបធៀបទៅនឹ ងការបំភាយការបំពុលខ្យល់ ដោយប្រយោលពី ការប្រើ ប្រាស់អគ្គិ សនី ការប្រើ ប្រាស់ប្រេងឥន្ធនៈផ្ទាល់នៅក្នុងរោងចក្រគឺ ជាប្រភពចម្បងក្នុងការបំពុលខ្យល់ដែលត្រូវយកមកពិ ចារណា។

ខាងក្រោមនេះ គឺ ជាលទ្ធផលនៃភាគល្អិ តនិ ចលដែលទទួលបានពី ការត្រួតពិ និ ត្យ គុណភាពខ្យល់នៅតាមរោងចក្រទាំង ១៦។

នៅថ្ងៃដែលក្រុមការងារបានធ្វើ ការត្រួតពិ និ ត្យ ភាគល្អិ តនិ ចលក្នុងអគារ និ ងក្រៅអគារនៅតាមរោងចក្រទាំងអស់គឺ ស្របទៅតាមគោលការណ៍ ណែនាំរបស់អង្គការសុខភាពពិ ភពលោកក្នុងការការការពារសុខភាពមនុស្ស (១៥g/m៣ ជាមធ្យម ២៤ ម៉ោង ឬ ៥g/m៣ ជាមធ្យមប្រចាំឆ្នាំ សម្រាប់ PM2.5 និ ង ៤៥g/m៣ ជាមធ្យម ២៤ ម៉ោង ឬ ១៥g/m៣ ជាមធ្យមប្រចាំឆ្នាំ សម្រាប់ PM10)។

មានករណី ដែលកំហាប់ភាគល្អិ តនិ ចល PM2.5 និ ង PM10 ក្នុងអគារប្រហែលគ្នា ឬទាបជាងកំហាប់ភាគល្អិ តនិ ចលក្រៅអគារ និ ងកំហាប់ស្តង់ដារកំណត់។ ក៏ប៉ុន្តែ មានរោងចក្រចំនួន៥ប៉ុណ្ណោះដែលមានកំហាប់ភាគល្អិ តនិ ចលក្នុងអគារមានការកើ នឡើ ងគួរឱ្យកត់សម្គាល់បើ ប្រៀបធៀបទៅនឹ ងភាគល្អិ តនិ ចលក្រៅ អគារ។ ជាធម្មតា ការវាស់វែងបែបនេះបង្ហាញថាខ្យល់ក្រៅ អគារបានជ្រៀតចូលទៅក្នុងអគារ ដោយនាំយកសភាគល្អិ តនិ ចលមកជាមួយជាជាងប្រភពពី ក្នុងអគារ។

លទ្ធផលគុណភាពខ្យល់ដែលត្រូវបានរកឃើ ញនៅតាមរោងចក្រដែលដុតអុសសម្រាប់ប្រើ ប្រាស់ជាឥន្ធនៈក្នុងដំណើ រការផលិ តសម្លៀកបំពាក់ មានកំហាប់ភាគល្អិ តនិ ចលកើ នឡើ ងខ្ពស់ជាងកម្រិ តស្តង់ដារដែលបានកំណត់។

រោងចក្រចំនួនប្រាំដែលប្រើ ប្រាស់អុសជាឥន្ធនៈបញ្ចេញសារធាតុពុលខ្លាំងជាងសារធាតុពុលផ្សេងទៀតដូចជា អាសូតអុកស៊ី ត (NOx) និ ងសមាសធាតុសរី រាង្គដែលមិ នមែនជាមេតាន (NMVOCs) (NOx និ ង NMVOCs) ក៏ប៉ុន្តែ ប្រភពឥន្ធនៈផ្សេងទៀតដូចជា ម៉ាស៊ូត សាំង និ ង LPG ក៏មានការបញ្ចេញសារធាតុពុលផងដែរ។

ចំពោះសារធាតុបំពុលខ្យល់ទាំងអស់ ការប្រើ ប្រាស់ប្រេងឥន្ធនៈដោយផ្ទាល់នៅតាមរោងចក្រមានការបញ្ចេញសារធាតុពុលច្រើ នជាងគេ បើ ប្រៀបធៀបនឹ ងការបញ្ចេញសារធាតុពុលដោយប្រយោល។ ចំពោះការបំភាយឧស្ម័ នផ្ទះកញ្ចក់ ដូចជាកាបូនឌី អុកស៊ី ត ($CO_2$) ការបំភាយដោយប្រយោលនៅរោងចក្រអគ្គិ សនី គឺ ជាប្រភពនៃការបញ្ចេញឧស្ម័ នកាបូនិ កដ៏ធំបំផុត ចំណែកឯ ដំណើ រការនៅតាមរោងចក្រកាត់ដេរដែលមានការប្រើ ហ្គាស ម៉ាស៊ូត និ ងសាំង ក៏បានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការបញ្ចេញសារធាតុពុលផងដែរ។

# បទពិសោធន៍របស់កម្មករទាក់ទងនឹងការយល់ដឹងពីការបំពុលខ្យល់

ដើម្បីស្វែងយល់ពីបទពិសោធន៍ និងការយល់ដឹងអំពីការបំពុលខ្យល់របស់កម្មករ ក្រុមការងារស្រាវជ្រាវបានសម្ភាសន៍កម្មករចំនួន ៣២៣ នាក់ មកពីរោងចក្រកាត់ដេរចំនួន ១៦ នៃប្រទេសកម្ពុជា។

ចំពោះសារធាតុបំពុលខ្យល់ទាំងអស់ ការប្រើប្រាស់ប្រេងឥន្ធនៈដោយផ្ទាល់នៅតាមរោងចក្រមានការបញ្ចេញសារធាតុពុលច្រើនជាងគេ បើប្រៀបធៀបនឹងការបញ្ចេញសារធាតុពុលដោយប្រយោល។ ចំពោះការបំភាយឧស្ម័នផ្ទះកញ្ចក់ ដូចជាកាបូនឌីអុកស៊ីត (CO2) ការបំភាយដោយប្រយោលនៅរោងចក្រអគ្គិសនី គឺជាប្រភពនៃការបញ្ចេញឧស្ម័នកាបូនិកដ៏ធំបំផុត ចំណែកឯដំណើរការនៅតាមរោងចក្រកាត់ដេរដែលមានការប្រើហ្គាស ម៉ាស៊ូត និងសាំង ក៏បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការបញ្ចេញសារធាតុពុលផងដែរ។

# បទពិសោធន៍របស់កម្មករទាក់ទងនឹងការយល់ដឹងពីការបំពុលខ្យល់

ដើម្បីស្វែងយល់ពីបទពិសោធន៍ និងការយល់ដឹងអំពីការបំពុលខ្យល់របស់កម្មករ ក្រុមការងារស្រាវជ្រាវបានសម្ភាសន៍កម្មករចំនួន ៣២៣ នាក់ មកពីរោងចក្រកាត់ដេរចំនួន ១៦ នៃប្រទេសកម្ពុជា។

# យេនឌ័រនិងការរងឥទ្ធិពលពីការបំពុលខ្យល់នៅក្នុងរោងចក្រកាត់ដេរ

ក្នុងចំណោមកម្មករដែលបានសម្ភាសន៍ កម្មករស្ត្រីមានចំនួន ៨៣% និងកម្មករជាបុរសមានចំនួន ១៦%។ នេះជាការឆ្លុះបញ្ចាំងពីវិសមភាពយេនឌ័រផ្នែកការងារនៅតាមរោងចក្រកាត់ដេរ។ ជាការពិត តាមការប៉ាន់ប្រមាណ ចំនួនកម្មករសរុបដែលធ្វើការក្នុងវិស័យកាត់ដេរ និងផលិតស្បែកជើងនៅកម្ពុជាមានប្រមាណ ១លាននាក់ ហើយប្រមាណ ៨០% ជាស្ត្រី (ILO, 2018)។ លើសពីនេះ លទ្ធផលសម្ភាសន៍ក៏បានបង្ហាញដែរថា កម្មករវ័យក្មេងក្នុងចំណោមអ្នកត្រូវបានសម្ភាសន៍អាយុចាប់ពី ១៨-២៥ឆ្នាំ មានចំនួន២២% អ្នកមានអាយុពី ២៥-៣៥ឆ្នាំ មានចំនួន៤៩% អ្នកមានអាយុពី ៣៥-៤៥ មានចំនួន២៦%

ហើយមានតែ៣% ប៉ុណ្ណោះដែលមានអាយុពី ៤៥-៥៥ឆ្នាំ។ ចំនួនកម្មករស្ត្រីវ័យក្មេងដែលមិនមានភាពសមាមាត្រនៅក្នុងការងាររោងចក្រកាត់ដេរ គឺស្រប តាមការចង់បានរបស់ផ្នែកឧស្សាហកម្មនៅទូទាំងអាស៊ី ក្នុងការជួលស្ត្រីវ័យក្មេងដែលជាធម្មតាធ្វើចំណាកស្រុកមកពីជនបទ ព្រោះតែពួកគេមានជីវភាពខ្វះខាត ហើយស្វែងរកការងារនៅតាមរោងចក្រកាត់ដេរដោយទទួលយកប្រាក់ឈ្នួលទាប។ ទោះជាយ៉ាងណាក៏ដោយ យើងមិនបានរកឃើញភាពខុសគ្នាគួរឱ្យកត់សម្គាល់ទាក់ទងនឹងការយល់ដឹងអំពីគុណភាពខ្យល់ និងផលប៉ះពាល់របស់វារវាងកម្មករជាបុរសនិងស្ត្រីឡើយ (តារាងទី ១)។

តារាងទី ១៖ លទ្ធផលសំខាន់ៗពីការស្ទង់មតិ បែងចែកតាមភេទ

តើការធ្វើការក្នុងរោងចក្រប៉ះពាល់ដល់សុខភាពឬទេ? %

| | បាទ/ចាស | ទេ | គ្មានយោបល់ |
|---|---|---|---|
| បុរស (n=53) | 7.55 | 90.57 | 1.89 |
| ស្ត្រី (n=270) | 5.55 | 93.70 | 0.74 |

តើអ្នកពាក់សម្លៀកបំពាក់ការពារ PPE ឬទេ? %

| | បាទ/ចាស | ទេ |
|---|---|---|
| បុរស (n=53) | 86.79 | 13.21 |
| ស្ត្រី (n=270) | 87.41 | 12.59 |

តើអ្នកពាក់សម្លៀកបំពាក់ការពារ PPE ឬទេ? %

| | ទទួលយកបាន | ល្អ | គ្មានយោបល់ | មិនដឹង | អាក្រក់ | ទទួលយកបាន (ក្តៅ) |
|---|---|---|---|---|---|---|
| បុរស (n=53) | 90.57 | 9.43 | 0.00 | 0.00 | 0.00 | 0.00 |
| ស្រី (n=270) | 86.67 | 8.65 | 0.37 | 0.37 | 0.37 | 0.37 |

# កង្វះការយល់ដឹងអំពីការបំពុលខ្យល់

កម្មករភាគច្រើនមិនដឹងច្បាស់ថា "គុណភាពខ្យល់" មានន័យដូចម្តេច ឬមានអ្វីរួមបញ្ចូលក្នុងនោះទេ ដោយពួកគេភាគច្រើនបានគិតថាវាពាក់ព័ន្ធនឹងសីតុណ្ហភាពទៅវិញ។ ជាលទ្ធផល កម្មករភាគច្រើនមិនបានដឹងច្បាស់ថារោគសញ្ញាប្រភេទណា ឬជំងឺអ្វីដែលបណ្តាលមកពីការបំពុលខ្យល់នោះទេ។ កម្មកររោងចក្រស្ទើរតែទាំងអស់ (៩៩%) បាននិយាយថា គុណភាពខ្យល់ នៅក្នុងកន្លែងធ្វើការរបស់ពួកគេអាចទទួលយកបាន ប៉ុន្តែពេលខ្លះពួកគេមានអារម្មណ៍ស្ពុះស្ពាប់ ជាពិសេសនៅរដូវប្រាំង (តារាងទី ១)។

ទោះបីជាមានការយល់ច្រឡំដូច្នេះក៏ដោយ នៅពេលដែលកម្មករត្រូវបានសួរអំពីបទពិសោធន៍របស់ពួកគេជាមួយនឹងរោគសញ្ញាជាក់លាក់ លទ្ធផលបានបង្ហាញឱ្យឃើញថា កម្មករដែលត្រូវបានសម្ភាសន៍ទាំងអស់បានជួបប្រទះយ៉ាងហោចណាស់រោគសញ្ញាមួយដែលអាចទាក់ទងនឹងការបំពុលខ្យល់ (សូមមើលរូបភាពទី ១) ។ តាមរបាយការណ៍ ស្ត្រីមានរោគសញ្ញាខ្ពស់ជាងបុរស (តារាងទី ២) ដែលមានចំនួន ២.៤% នៃកម្មករជាស្ត្រីឆ្លើយថា «ជាញឹកញាប់» បើប្រៀបធៀបទៅនឹងបុរសដែលមានចំនួនតិចជាង ១%។ ទោះជាយ៉ាងណាក៏ដោយ ទាក់ទងនឹងការយល់ឃើញវិញ កម្មករជាស្ត្រីមិនសូវគិតថាគុណភាពខ្យល់បានប៉ះពាល់ដល់សុខភាពរបស់ពួកគេទេ (តារាងទី ១)។

រូបភាពទី ១៖ ភាពញឹកញាប់នៃរោគសញ្ញាដែលកម្មករនៅក្នុងរោងចក្របានជួបប្រទះ ដោយមិន បានបែងចែកតាមយេនឌ័រ

ក. រោគសញ្ញាកើតឡើងជាញឹកញាប់    ខ. រោគសញ្ញាកើតឡើងជាញឹកញាប់៖ ៦ខែកន្លងមក




តារាងទី ២៖ ភាពខុសគ្នានៃយេនឌ័រដែលបានរាយការណ៍អពីរោគសញ្ញាដែលកើតឡើងញឹកញាប់

| បុរស | | | |
|---|---|---|---|
| | ញឹកញាប់ | ម្តងម្កាល | មិនដែល |
| ក្អក | ០ | ១៦ | ៣៧ |
| ស្ងួតក | ០ | ១២ | ៤១ |
| ហៀរសំបោរ | ០ | ២៤ | ២៩ |
| ឈឺក្បាល | ១ | ២៤ | ២៨ |
| ឈឺភ្នែក | ១ | ១២ | ៤០ |
| អស់កម្លាំង | ១ | ១៨ | ៣៤ |
| ឈឺសួត | ០ | ១ | ៥២ |
| ផ្សេងៗ | ០ | ០ | ៥៣ |
| សរុប (៤២៤) | ៣ | ១០៧ | ៣១៤ |
| គិតជាភាគរយ | ១% | ២៥% | ៧៤% |
| | | | |
| ស្ត្រី | | | |
| | ញឹកញាប់ | ម្តងម្កាល | មិនដែល |
| ក្អក | ៥ | ១០១ | ១៦៤ |
| ឈឺក | ៥ | ៦៦ | ១៩៩ |
| ហៀរសំបោរ | ២ | ១៣៩ | ១២៩ |
| ឈឺក្បាល | ២០ | ១៥៩ | ៩១ |
| ឈឺភ្នែក | ៨ | ៥៤ | ២០៨ |
| អស់កម្លាំង | ១២ | ៩៥ | ១៦៣ |
| ឈឺសួត | ១ | ០ | ២៦៩ |
| ផ្សេងៗ | ០ | ២ | ២៦៨ |
| សរុប (២១៦០) | ៥៣ | ៦១៦ | ១៤៩១ |
| គិតជាភាគរយ | ២% | ២៨% | ៦៩% |

# បទពិសោធន៍របស់ម្ចាស់រោងចក្រ និងការយល់ដឹងពីការបំពុលខ្យល់

ម្ចាស់រោងចក្រដែលបានសម្ភាសន៍ទាំង ១៦នាក់ បានឆ្លើយថា ពួកគេបានចាត់វិធានការកែលម្អគុណភាពខ្យល់ និងទប់ស្កាត់កម្មករពីការការបំពុលខ្យល់៖ ឧទាហរណ៍  ការរក្សាទុកសារធាតុគីមី និងវត្ថុធាតុដើមឱ្យបានត្រឹមត្រូវ និងបំបែកចេញពីអគារផលិតកម្ម ក្រុមហ៊ុនឯកជនបានប្រមូលកាកសំណល់ ហើយពួកគេបានផ្តល់ឧបករណ៍ការពារក៏ដូចជាចំណេះដឹងស្តីពីការអនុវត្តប្រកប ដោយសុវត្ថិភាព និងការការពារសុខភាពដល់កម្មករផងដែរ។ ទោះជាយ៉ាងណាក៏ដោយ បើយោងតាមការឆ្លើយតបទៅនឹងបទសម្ភាសន៍ មានម្ចាស់រោងចក្រតែ ៥០% ប៉ុណ្ណោះដែលធ្វើការត្រួតពិនិត្យគុណភាពខ្យល់ប្រចាំឆ្នាំ ឬមួយឆ្នាំម្តង ។

ម្ចាស់រោងចក្រទាំងនោះបាននិយាយថា ពួកគេបានកំពុងព្យាយាមចាត់វិធានការដើម្បីកែលម្អគុណភាពខ្យល់នៅក្នុងរោងចក្រ រួមមានការដំឡើងកង្ហារត្រជាក់ ឬប្រព័ន្ធខ្យល់ចេញចូល ការបែងចែកចំនួនកម្មករតាមទំហំអគារ និងការអនុវត្តការសន្សំសម្ចៃថាមពល (ការប្រើប្រាស់ ម៉ាស៊ីន និងគ្រឿងបរិក្ខារដែលប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព (គ្រឿងបរិក្ខារដែល ស៊ីភ្លើងតិច) ការលើកកម្ពស់ទម្លាប់សន្សំសំចៃថាមពល) ក៏ដូចជាការបំបែកអគារផលិតកម្មចេញពីកន្លែងផ្ទុក ឬអគារដាក់សម្ភារៈ។ ពួកគេបានយល់ឃើញថាគុណភាពខ្យល់នៅក្នុងអគារផ្សេងៗគ្នាអាចទទួលយកបាន ជាពិសេសប្រសិនបើអគារផលិតកម្មត្រូវបានបំពាក់ដោយកង្ហារ និងកង្ហារបឺតខ្យល់ ឬប្រព័ន្ធទឹកត្រជាក់ (Water Cooler) ឬទឹកផឹកសម្រាប់កម្មករកាន់តែប្រសើរ។

# អនុសាសន៍ផ្នែកគោលនយោបាយ

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវដូចបានរៀបរាប់ខាងលើ ក្រុមការងារបានផ្តល់នូវអនុសាសន៍គោលនយោបាយមួយចំនួន ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងទាក់ទងនឹងវិសមភាពយេនឌ័រ ការយល់ដឹងអំពីគុណភាពខ្យល់ និងផលប៉ះពាល់នៃការបំពុលខ្យល់ ដូចខាងក្រោម៖

ជារួម គុណភាពខ្យល់នៅតាមរោងចក្រមួយចំនួនបានអនុលោមតាមស្តង់ដារគុណភាពខ្យល់ជាតិកម្ពុជា ប៉ុន្តែរោងចក្រខ្លះមានគុណភាពខ្យល់លើសពីកម្រិតដែលបានណែនាំដោយអង្គការសុខភាពពិភពលោក (WHO) ។ ដូចនេះ ការពិនិត្យតាមដានគុណភាពខ្យល់នៅតាមរោងចក្រវាយនភណ្ឌ និងកាត់ដេរសម្លៀកបំពាក់ គួរតែធ្វើឱ្យបានទៀងទាត់។

គោលនយោបាយ និងបទប្បញ្ញត្តិស្តីពីការបំពុលខ្យល់ក្នុងអគារ និងក្រៅអគារត្រូវបានបង្កើតឡើងដោយក្រសួងបរិស្ថាន និងភ្នាក់ងារដៃគូរបស់កម្ពុជា ហើយវាគួរតែត្រូវបានពង្រីករហូតដល់គ្រប់រោងចក្រទាំងអស់។ ឧទាហរណ៍ កម្មវិធី «ប្រសិទ្ធិភាពធនធាន និងផលិតកម្មស្អាត» គ្រប់គ្រង \ដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI) ក្នុងគោលបំណងកាត់បន្ថយការបំភាយឧស្ម័ននៅក្នុងវិស័យឧស្សាហកម្ម ខណៈដែលអង្គការពលកម្មអន្តរជាតិ (ILO) ដំណើរការគំនិតផ្តួចផ្តើម «គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា» ដើម្បីធានាបានលក្ខខណ្ឌការងារ និងផលិតភាពល្អប្រសើរនៅក្នុងវិស័យ កាត់ដេរ ដោយរួមទាំងសុខភាព និងសុវត្ថិភាពរបស់កម្មករផងដែរ។ សេនាធិការរបស់រាជរដ្ឋាភិបាលមានដូចជានាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់ សំឡេង និងរំញ័រគួរតែពង្រឹងការអនុវត្តកម្មវិធី និងបទប្បញ្ញត្តិដែលមានស្រាប់ដូចជាអនុក្រឹត្យស្តីពីការគ្រប់គ្រងការបំពុលខ្យល់ និងការរំខានដោយសំឡេង ដើម្បីរក្សាលក្ខខណ្ឌការងារអំណោយផលដែលនឹងផ្តល់អត្ថប្រយោជន៍ដល់សុខភាពកម្មករតាមរយៈការធ្វើអធិការកិច្ចឱ្យបានញឹកញាប់។

វិសមភាពយេនឌ័រនៅក្នុងវិស័យកាត់ដេរ បានស្នើឡើងថា គោលនយោបាយដែលទាក់ទងនឹងវិស័យកាត់ដេរគួរតែទទួលស្គាល់យ៉ាងច្បាស់អំពីវិសមភាពយេនឌ័រដែលកំណត់លក្ខណៈនៃវិស័យនេះ ជាពិសេសចំនួនមិនសមាមាត្រនៃកម្មករស្ត្រីវ័យក្មេងនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់នៃវិស័យកាត់ដេរ។ គោលនយោបាយការងារដែលមានស្រាប់ គួរតែស្របតាមក្របខណ្ឌអន្តរជាតិដែលពាក់ព័ន្ធស្តីពីយេនឌ័រ និងការអនុវត្តការងារ។ ឧទាហរណ៍ អនុសញ្ញាសំខាន់ៗរបស់អង្គការពលកម្មអន្តរជាតិ ស្តីពីយេនឌ័ររួមមានអនុសញ្ញាស្តីពីការកំណត់ចំនួនស្មើគ្នា អនុសញ្ញាស្តីពីការរើសអើង (ការងារ និងមុខរបរ) អនុសញ្ញាស្តីពីការទទួលខុសត្រូវលើកម្មករ និងគ្រួសារ អនុសញ្ញា ស្តីពីការការពារមាតុភាព និងអនុសញ្ញាស្តីពីអពើហឹង្សា និងការបៀតបៀន។ ជាមួយគ្នានេះដែរ គោលនយោបាយថ្មីៗទាក់ទងនឹងវិស័យកាត់ដេរ ដូចជាក្រមថ្មីស្តីពីសុវត្ថិភាពការងារ និងសុខភាព គួរតែដាក់បញ្ចូលយេនឌ័រផងដែរ។ គោលនយោបាយនោះចាំបាច់ត្រូវតែធានានូវបញ្ញត្តិដែល លើកឡើងពីតម្រូវការជាក់លាក់របស់កម្មករស្ត្រី រួមទាំងសុវត្ថិភាពការងារ ការបង្ការ និងការទទួលស្គាល់ហានិភ័យ នៃការបំពុលខ្យល់ដល់កម្មករស្ត្រី ជាពិសេសអំឡុងពេលមានផ្ទៃពោះ។ ហានិភ័យក្នុងអំឡុងពេលមានផ្ទៃពោះរួមមានការរំលូតកូន ការកើតមិនគ្រប់ខែ និងទារកមានទម្ងន់ស្រាល (Ghosh et al., 2021)។

គោលនយោបាយផ្សេងៗទៀតគួរតែដាក់ឱ្យអនុវត្តបន្ថែមទៀតដើម្បីធានាឱ្យមានដំណើរការជាផ្លូវការនៃការងារក្នុងវិស័យកាត់ដេរ និងធានាសិទ្ធិរបស់កម្មករក្នុងការធានារ៉ាប់រងសុខភាព និងការឈប់សម្រាកដែលមានប្រាក់ឈ្នួល និងធានាបាននូវប្រាក់ឈ្នួលសមរម្យសម្រាប់កម្មករស្ត្រី ជាពិសេសនៅក្នុងផ្នែកដែលមានកិច្ចសន្យាបន្តដែលពុំមានការគ្រប់គ្រងត្រឹមត្រូវ។ ការចាប់ផ្តើមឱ្យមានប្រាក់ឧបត្ថម្ភក្នុងការ លំហែមាតុភាពដល់កម្មករកាត់ដេរ១ ពីបេឡាជាតិរបបសន្តិសុខសង្គម ក៏ដូចជាការធានារ៉ាប់រងគ្រោះថ្នាក់ការងារ និងការធានារ៉ាប់រងសុខភាពសង្គមត្រូវបានស្វាគមន៍ ប៉ុន្តែវានៅតែតម្រូវឱ្យមានការចាត់វិធានការ ដើម្បីធានាថាកម្មករបានដឹងច្បាស់អំពីអត្ថប្រយោជន៍ទាំងនេះ និងកំណត់អត្តសញ្ញាណនិយោជកដែលខ្វះសីលធម៌ ដើម្បីឱ្យមានការទទួល ខុសត្រូវ។ ជាងនេះទៅទៀត សហជីព និងអង្គការសង្គមស៊ីវិលគួរតែសម្របសម្រួលកិច្ចសន្ទនាសង្គម និងការយល់ដឹងក្នុងចំណោមកម្មករកាត់ដេរដែលគាំទ្រដោយគោលនយោបាយការងារពាក់ព័ន្ធនានា ដើម្បីលើកទឹកចិត្តកម្មករជាពិសេសស្ត្រីឱ្យអនុវត្តសិទ្ធិរបស់ពួកគេនៅកន្លែងធ្វើការ។

អង្គការសុខភាពពិភពលោក (WHO) អាចផ្តល់នូវការចូលរួមកាន់តែច្រើននៅក្នុងវិស័យកាត់ដេរ ដោយផ្តល់ការបណ្តុះបណ្តាលអំពីគោលការណ៍ណែនាំរបស់អង្គការសុខភាពពិភពលោកដល់មន្ត្រីរដ្ឋាភិបាល និងបុគ្គលិករោងចក្រដែលទទួល បន្ទុកការការពារសុខភាព។

ការសិក្សាបានបង្ហាញថាកម្មករមានការយល់ដឹងតិចតួចអំពីគុណភាពខ្យល់។ ប្រសិនបើកម្មករបានទទួលការបណ្តុះបណ្តាល ហើយមនុស្សកាន់តែច្រើនយល់ដឹងពីការបំពុលខ្យល់ និងផលប៉ះពាល់ដល់សុខភាព និងផលិតភាពរបស់រោងចក្រ ចំណេះដឹងនេះគួរតែផ្តល់ការលើកទឹកចិត្តក្នុង ការធ្វើឱ្យគុណភាពខ្យល់កាន់តែប្រសើរឡើង។ ការលើកកម្ពស់ការយល់ដឹងអំពីការបំពុលខ្យល់ និងផលប៉ះពាល់សុខភាពក្នុងចំណោមកម្មករ នឹងជួយឱ្យពួកគេយល់ដឹងកាន់តែច្រើនអំពីការបំពុលខ្យល់ និងការអនុវត្តវិធានការការពារសុខភាព។ សហជីព ភ្នាក់ងារសុខាភិបាល និងអង្គការ ក្រៅរដ្ឋាភិបាលអាចធ្វើយុទ្ធនាការអប់រំ និងការងារទំនាក់ទំនងផ្សេងទៀត។

ស្ថាប័នរដ្ឋ និងឯកជនដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយវិស័យកាត់ដេរ ដូចជាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្នែកមួយនៃក្រសួង ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ គួរតែធ្វើការសហការជាមួយអង្គការ ពលកម្មអន្តរជាតិ អ្នកបញ្ជាទិញ និងសង្គមស៊ីវិល ដើម្បីធានាថាគ្រប់រោងចក្រកាត់ដេរទាំងអស់អនុលោមតាមស្តង់ដារដែលបានកំណត់។

វិទ្យាស្ថានបរិស្ថានស្តុកខុម គឺជាអង្គការស្រាវជ្រាវ និងគោលនយោបាយមិនរកប្រាក់ចំណេញអន្តរជាតិ ដែលដោះស្រាយបញ្ហាប្រឈមនានាផ្នែកបរិស្ថាន និងការអភិវឌ្ឍន៍។ យើងភ្ជាប់វិទ្យាសាស្ត្រ និងការ សម្រេចចិត្ត ដើម្បីបង្កើតដំណោះស្រាយសម្រាប់អនាគតប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់គ្នា។ វិធីសាស្ត្ររបស់យើងគឺការសហការគ្នាយ៉ាងសកម្ម៖ ការចូលរួមរបស់ភាគីពាក់ព័ន្ធ គឺជាបេះដូងនៃកិច្ចខិតខំប្រឹងប្រែងរបស់យើងក្នុងការកសាងសមត្ថភាព ការពង្រឹងស្ថាប័ន និងគាំទ្រដៃគូសហការសម្រាប់រយៈពេលវែង។ ការងាររបស់យើងគ្របដណ្តប់លើបញ្ហាអាកាសធាតុ ទឹក ខ្យល់ និងការប្រើប្រាស់ដី ដោយរួមបញ្ចូលកស្តុតាង និងទស្សនៈស្តីពីអភិបាលកិច្ច សេដ្ឋកិច្ច យេនឌ័រ និងសុខភាពមនុស្ស។ តាមរយៈមជ្ឈមណ្ឌលទាំងប្រាំបីរបស់យើងនៅអឺរ៉ុប អាស៊ី អាហ្វ្រិក និងអាមេរិក យើងចូលរួមជាមួយដំណើរការគោលនយោបាយ សកម្មភាពអភិវឌ្ឍន៍ និងការធ្វើអាជីវកម្មទូទាំងពិភពលោក។

ការបោះពុម្ពនេះគឺជាលទ្ធផលនៃគម្រោង «ផលប៉ះពាល់នៃការបំពុលខ្យល់លើពិភពនៃការងារសម្រាប់ស្ត្រី និងយុវជននៅអាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍« ដែលជាគំនិតផ្តួចផ្តើមរួមគ្នារវាងមជ្ឈមណ្ឌលស្រាវជ្រាវ

អភិវឌ្ឍន៍អន្តរជាតិ (IDRC) នៃប្រទេសកាណាដា អង្គការពលកម្មអន្តរជាតិ (ILO) និងវិទ្យាស្ថានបរិស្ថានស្តុកខុម (SEI) ក្នុងបរិបទនៃគំនិតផ្តួចផ្តើមសកលរបស់អង្គការសហប្រជាជាតិស្តីពីការងារសមរម្យសម្រាប់យុវជន។ គម្រោងនេះត្រូវបានផ្តល់មូលនិធិដោយ IDRC ក្រោមជំនួយឥតសំណងលេខ 109451 001 ដែលដឹកនាំ និងអនុវត្តដោយ SEI និងគាំទ្រផ្នែកបច្ចេកទេសដោយ ILO។ ខ្លឹមសារនៃឯកសារនេះគឺជាទំនួលខុសត្រូវតែមួយគត់របស់អ្នកសិក្សាស្រាវជ្រាវហើយវាមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់អង្គការ ពលកម្មអន្តរជាតិ ឬគំនិតផ្តួចផ្តើមសកលរបស់អង្គការសហប្រជាជាតិស្តីពីការងារសមរម្យសម្រាប់យុវជន ឬសកម្មភាពអាកាសធាតុសម្រាប់គំនិតផ្តួចផ្តើមការងារនោះទេ។

# ឯកសារយោង


Asian Development Bank. (2013). Gender Equality in the Labor Market in Cambodia. ISBN 978-92-9254-401-0 https://hdl.handle. net/11540/795

Chandath, H., Chhay Por, I., Sokyimeng, S., Dana, S., & Raksmey, Y. (2023). Understanding Air Pollution in the Garment Sector and Health Impacts on Workers: A Cambodian Case Study. Ministry of Environment, Cambodia. https://epa.moe.gov.kh/ pages/categories/ view/document-daqnm

Ghosh, R., Causey, K., Burkart, K., Wozniak, S., Cohen, A., & Brauer, M. (2021). Ambient and household PM2.5 pollution and adverse perinatal outcomes: a meta-regression and analysis of attributable global burden for 204 countries and territories. PLoS Med. 18(9). https://journals.plos.org/plosmedicine/ article?id=10.1371/journal.pmed.1003718

International Labour Organization. (2018). Living conditions of garment and footwear sector workers in Cambodia. Cambodia Garment and Footwear Sector Bulletin (Issue 8). https://www.ilo.org/ wcmsp5/groups/ public/---asia/---ro-bangkok/ documents/ publication/wcms_663043.pdf

Kingdom of Cambodia. (2019.) Report on the Cambodia Labour Force Survey 2019. https://nis.gov.kh/index. php/en/28-clfs/98- cambodia-labour-force-survey-2019-clfs

Lawreniuk, S., & Nuon, V. (2022.) Social Protection for the Apparel Industry in Cambodia: Gaps and Opportunities. Oxfam Cambodia. https://cambodia. oxfam.org/ latest/publications/social-protection-apparel-industry-cambodia-gaps-and-opportunities?q=latest/policy-paper/ social-protection-apparel-industry- cambodia-gaps-and-opportunities

Merk, J & Nuon, V. (2016.) Country Study Cambodia – Labour Standards in Garment Supply Chain. CNV International. https:// www.cnvinternationaal.nl/_ Resources/ Persistent/0/e/0/5/0e05eebdbf4a1a6c31 409dc12a ee83b8f532a4b5/20161102%20 CNV%20CS%20 Cambo_clickable%20 extern%20ENG%20DEF.pdf

MOE & GGGI. (2016). Phnom Penh Green City Strategic Plan 2017-2026. Ministry of Environment and Global Green Growth Institute. https://ncsd.moe. gov.kh/sites/ default/files/2019-05/Phnom%20 Penh%20 Green%20Strategic%20Plan.pdf



ការបោះពុម្ពនេះគឺ ជាលទ្ធផលនៃគម្រោង «ផលប៉ះពាល់នៃការបំពុលខ្យល់លើ ពិភពនៃការងារសម្រាប់ស្ត្រី និងយុវជននៅអាស៊ី បូព៌ា និងអាស៊ី អាគ្នេយ៍ « ដែលជាគំនិតផ្តួចផ្តើមរួមគ្នារវាងមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍ អន្តរជាតិ (IDRC) នៃប្រទេសកាណាដា អង្គការពលកម្មអន្តរជាតិ (ILO) និងវិទ្យាស្ថានបរិស្ថានស្តុកខុម (SEI) ក្នុងបរិបទនៃគំនិតផ្តួចផ្តើមសកលរបស់អង្គការសហប្រជាជាតិ ស្តីពី ការងារសមរម្យសម្រាប់យុវជន។ គម្រោងនេះត្រូវបានផ្តល់មូលនិធិ ដោយ IDRC ក្រោមជំនួយឥតសំណងលេខ 109451 001 ដែលដឹកនាំ និងអនុវត្តដោយ SEI និងគាំទ្រផ្នែកបច្ចេកទេសដោយ ILO។ ខ្លឹមសារនៃឯកសារនេះគឺ ជាទំនួលខុសត្រូវតែមួយគត់របស់អ្នកសិក្សាស្រាវជ្រាវហើយវាមិនឆ្លុះបញ្ចាំងពី ទស្សនៈរបស់អង្គការ ពលកម្មអន្តរជាតិ ឬគំនិតផ្តួចផ្តើមសកលរបស់អង្គការសហប្រជាជាតិ ស្តីពី ការងារសមរម្យសម្រាប់យុវជន ឬសកម្មភាពអាកាសធាតុសម្រាប់គំនិតផ្តួចផ្តើមការងារនោះទេ។



Stockholm Environment Institute

បោះពុម្ពដោយ
វិទ្យាស្ថានបរិស្ថានស្តុកខុម
Linnégatan 87D, Box 24218
104 51 Stockholm, Sweden
Tel: +46 8 30 80 44



DOI:
https://doi.org/10.51414/sei2023.001



ទំនាក់ទំនងអ្នកនិពន្ធ
diane.archer@sei.org

ទំនាក់ទំនងប្រព័ន្ធផ្សព្វផ្សាយ
rajesh.daniel@sei.org

Visit us: sei.org
Twitter: @SEIresearch
@SEIclimate



វិទ្យាស្ថានបរិស្ថានស្តុកខុម គឺជាអង្គការស្រាវជ្រាវ និងគោលនយោបាយមិនរកប្រាក់ចំណេញ អន្តរជាតិ ដែលដោះស្រាយបញ្ហាប្រឈមនានាផ្នែកបរិស្ថាន និងការអភិវឌ្ឍន៍។ យើងភ្ជាប់វិទ្យាសាស្ត្រ និងការ សម្រេចចិត្ត ដើម្បីបង្កើតដំណោះស្រាយសម្រាប់អនាគតប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់គ្នា។ វិធីសាស្ត្ររបស់យើងគឺការសហការគ្នាយ៉ាងសកម្ម៖ ការចូលរួមរបស់ភាគីពាក់ព័ន្ធគឺជាបេះដូងនៃកិច្ចខិតខំប្រឹងប្រែងរបស់យើងក្នុងការកសាងសមត្ថភាព ការពង្រឹងស្ថាប័ន និងគាំទ្រដៃគូសហការសម្រាប់រយៈពេលវែង។ ការងាររបស់យើងគ្របដណ្តប់លើបញ្ហាអាកាសធាតុ ទឹក ខ្យល់ និងការប្រើប្រាស់ដី ដោយរួមបញ្ចូលភស្តុតាង និងទស្សនៈស្តីពីអភិបាលកិច្ច សេដ្ឋកិច្ច យេនឌ័រ និងសុខភាពមនុស្ស។ តាមរយៈ មជ្ឈមណ្ឌលទាំងប្រាំបីរបស់យើងនៅអឺរ៉ុប អាស៊ី អាហ្វ្រិក និងអាមេរិក យើងចូលរួមជាមួយដំណើរការគោលនយោបាយ សកម្មភាពអភិវឌ្ឍន៍ និងការធ្វើអាជីវកម្មទូទាំងពិភពលោក។


IDRC · CRDI
International Development Research Centre
Centre de recherches pour le développement international

Canada

International Labour Organization